**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

**ខុមហ្វ្រែល COMFREL** P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ០៦/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត ឧត្តរមានជ័យ

*ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨៥នាក់ មកពីស្រុកនានា និងក្រុងនៅក្នុងខេត្តឧត្តរមានជ័យនិងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ១៩% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩ ក្នុងខេត្តឧត្តរមានជ័យ ។

ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ឯកឧត្តម **យឹម ធីន** បានមានប្រសាសន៍បើកនៅក្នុងសិក្ខាសាលា ថា ប្រជាពលរដ្ឋត្រូវតែបញ្ចេញមតិយោបល់ និងតំរូវការដែលខ្លួនចង់បាននៅក្នុងមណ្ឌលរបស់ខ្លួន ហើយតំរូវការនោះធ្វើយ៉ាងណាអោយវាសមស្របទៅនឹងភាពជាក់ស្តែង និងចាំបាច់នៅក្នុងខេត្ត។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តឧត្តរមានជ័យដូចខាងក្រោម:

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តឧត្តរមានជ័យរួមមាន:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងខេត្ត ឧត្តរមានជ័យ** |
|---|
| ១) សុំឱ្យរាជរដ្ឋាភិបាលជួយតបណ្តាញអគ្គិសនីអោយបានគ្រប់ស្រុកក្នុងខេត្តឧត្តរមានជ័យជូនដល់ប្រជាពលរដ្ឋក្នុងខេត្ត ដោយចាប់ផ្តើមរៀបចំអោយបាននៅឆ្នាំ២០១២ ។សុំឱ្យដាក់ទោសដល់ក្រុមហ៊ុនមិនទទួលយករូបិយប័ណ្ណខ្មែរនិងសុំអោយកំណត់តម្លៃអគ្គីសនី ៥០០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងចាប់ពីឆ្នាំ២០១០ តទៅ។ សុំបញ្ចុះតម្លៃសេវាតភ្លើងចូលផ្ទះឱ្យបាន៥០%នៃតម្លៃបច្ចុប្បន្នឱ្យបានចាប់ពីឆ្នាំ ២០១០តទៅ ។ |
| ២) សុំរាជរដ្ឋាភិបាលជួយក្រាលកៅស៊ូលើផ្លូវ ចំនួន ៣ខ្សែ។ ខ្សែទី១ ពីសង្កាត់អូរស្មាច់ ក្រុងសំរោង ទៅស្រុកក្រឡាញ់ ក្នុងខេត្តសៀមរាប និងពីក្រុងសំរោង ទៅឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មានប្រវែង ១៧៥គម ខ្សែទី២ ពីក្រុងសំរោង ទៅភូមិជើងភ្នំ ក្នុងសង្កាត់បន្ទាយរាក់ ក្រុងសំរោង មានប្រវែង ៤០គម និងខ្សែទី៣ ចាប់ពីស្រុកអន្លង់វែង ដល់ស្រុកសំរោង មាន ប្រវែង ៨២គម ដោយផ្តើមកសាងក្នុងឆ្នាំ២០១០ និងបញ្ចប់ក្នុងឆ្នាំ២០១២។ |

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើត ស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ៣) សុំបង្កើតមជ្ឈមណ្ឌលសំរាប់បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងផ្តល់ពូជផលិតផល ដូចជា ស្រូវ ( ស្រូវស្រាល) ពោត ដំឡូង ដំណាំផ្សេងៗ... និងផ្តល់បច្ចេកទេសធ្វើជីធម្មជាតិ ឱ្យបានមួយកន្លែង ក្នុងមួយស្រុក ដល់កសិករទូទាំងខេត្ត ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១១។ |
| ៤) សុំអោយរាជរដ្ឋាភិបាលជួយរកវិយោគិនមកធ្វើរោងចក្រស្ករស [ យ៉ាងហោច ១ កន្លែង ] នៅក្រុងសំរោងអោយបាននៅឆ្នាំ២០១០ ហើយមានឈ្មួញ ឬអ្នកវិនិយោគទិញអំពៅតាមតម្លៃទីផ្សារ ឬមានកិច្ចកុងត្រាទិញ ១ តោនអំពៅ ស្មើ ២០ ដុល្លារអាមេរិក។ |
| ៥) សុំប្រឡាយទឹក ១ខ្សែ មានប្រវែង ២០០០ម x ២ម ( ផ្ទៃបាតលើ) x ១.៥០ម ( ផ្ទៃបាតក្រោម) នៅសង្កាត់បន្ទាយរាក់ ក្រុងសំរោង ដោយចាប់ផ្តើមនៅឆ្នាំ២០១០ បញ្ចប់ក្នុងឆ្នាំ២០១១។ |
| ៦) សុំឱ្យសភាពាណិជ្ជកម្ម ប្រកាសតម្លៃផលិតផល ដូចជា ពោត ស្រូវ សណ្តែក ដំឡូង... ៣ដង ក្នុងមួយឆ្នាំ និងបង្កើនតម្លៃ ឱ្យបាន ២០% នៃតម្លៃផលិតផលបច្ចុប្បន្ន អោយបានចាប់ពីឆ្នាំ ២០០៩ នេះតទៅ។ |
| ៧) សុំអោយរាជរដ្ឋាភិបាលជួយរកវិនិយោគិនធ្វើរោងចក្រម្សៅមី [ យ៉ាងហោច ១ កន្លែង ] នៅក្រុងសំរោង ឱ្យបាននៅឆ្នាំ២០១០ និងមានឈ្មួញ ឬវិនិយោគិន ទិញដំឡូងមីស្រស់ ៤០០រៀល ក្នុង ១គីឡូក្រាម និងស្ងួត ៨០០រៀល ក្នុងមួយគីឡូក្រាម។ |
| ៨) សុំមន្ទីរសុរិយោដីខេត្តចុះបញ្ជីដីធ្លីដល់ប្រជាជន ( ប្រព័ន្ធ) បញ្ឈប់ការយកតម្លៃសេវា ដោយចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ តទៅ។ |
| ៩) សុំជួយដោះស្រាយដីសម្បទានសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រគ្មានដីប្រហែលចំនួន១៥០០គ្រួសារទូទាំងខេត្តឧត្តរមានជ័យយ៉ាងហោចណាស់ឱ្យបាន ២ហិកតា ក្នុង ១គ្រួសារ ដោយចាប់ផ្តើមនៅឆ្នាំ២០១០ បញ្ចប់នៅក្នុងឆ្នាំ២០១១។ |
| ១០) សុំអោយរាជរដ្ឋាភិបាលតម្លើងប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀនជាអប្បបរមាឱ្យបានចំនួន ៤០ម៉ឺនរៀល ក្នុងមួយខែ និងបន្ថែម ២០% នៃប្រាក់ខែ ចាប់ពីឆ្នាំ២០១០នេះតទៅ ។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD), សហគមន៍អភិវឌ្ឍន៍កុមារ (CDA), អង្គការសមាហរណកម្មអភិវឌ្ឍន៍សហគមន៍ (CIDO), សម្ព័ន្ធសិទ្ធិមនុស្ស និងសុខភាពកម្ពុជា (CHHRA) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោងនៅក្នុងខេត្តឧត្តរមានជ័យ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល ( ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:*


- លោក **គឹម ឈន** អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៩
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦